អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- យន្តការពាណិជ្ជកម្មថ្មីរបស់ចក្រភពអង់គ្លេស អាចនឹងជួយដល់បណ្តាក្រុមហ៊ុននាំចេញរបស់កម្ពុជា
- ការនាំចេញកម្ពុជាសម្រេចបាន ៨ប៊ីលានដុល្លារអាមេរិក គិតត្រឹមឆមាសទី១ ឆ្នាំ២០២១
- កម្ពុជា គាំទ្រសេចក្តីថ្លែងការណ៍ ស្តីពីនិរន្តរភាព នៃផលិតកម្មកសិកម្ម និងប្រព័ន្ធស្បៀងអាហារ
- ការផ្គត់ផ្គង់ "ជ្រូកសាច់រស់"ក្នុងស្រុកមានរហូតដល់៨៥%
- ពោតក្រហមនៅខេត្តត្បូងឃ្មុំ កំពុងមានទីផ្សារ និងតម្លៃល្អ ធ្វើឱ្យកសិករកំពុងទទួលបានប្រាក់ចំណេញ
- ក្រសួងហិរញ្ញវត្ថុរបស់ប្រទេសវៀតណាម បានស្នើដំឡើងអត្រាពន្ធគយលើការនាំចេញនូវផលិតផលមាស
- ពិដានថវិកាឆ្នាំ២០២២ របស់ប្រទេសហ្វីលីពីនត្រូវបានកម្រិតក្នុងបរិមាណជាង ៥ទ្រីលានប៉េសូ
- អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូណេស៊ី សម្រាប់ខែមិថុនា ឆ្នាំ២០២១
- ពាណិជ្ជកម្មថៃ ជាមួយដៃគូសំខាន់ៗ សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១
- ការលក់រាយរបស់សហរដ្ឋអាមេរិកកើនឡើង ០.៦% ក្នុងខែមិថុនា
- ការធ្លាក់ចុះសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានបញ្ចប់នៅខែមេសាឆ្នាំ២០២០ ដែលជាកំណត់ត្រារយៈពេលខ្លីបំផុត
- ប្រទេសជប៉ុន រក្សាការវាយតម្លៃសេដ្ឋកិច្ចនៅក្នុងរបាយការណ៍ខែកក្កដា

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### យន្តការពាណិជ្ជកម្មថ្មីរបស់ចក្រភពអង់គ្លេស អាចនឹងជួយដល់បណ្តាក្រុមហ៊ុននាំចេញរបស់កម្ពុជា



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ KT/Chor Sokunthea*

យោងតាមប្រសាសន៍របស់លោកស្រី Tina Redshaw ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា បានឱ្យដឹងថា គម្រោងពាណិជ្ជកម្មជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (Developing Countries Trading Scheme/DCTS) របស់ចក្រភពអង់គ្លេស គឺជាការបង្ហាញពីគោលបំណងរបស់អង់គ្លេសក្នុងការជំរុញពាណិជ្ជកម្មសេរី និងយុត្តិធម៌សកល ក៏ដូចជាបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះប្រទេសកម្ពុជា ដោយអនុញ្ញាតឱ្យអាជីវកម្មរបស់កម្ពុជា អាចចូលទៅកាន់ទីផ្សារចក្រភពអង់គ្លេស បានកាន់តែងាយស្រួល។ គម្រោង DCTS បានដាក់ចេញនូវវិធីសាស្ត្រនៃការអនុគ្រោះទីផ្សាររបស់រាជរដ្ឋាភិបាលអង់គ្លេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានដូចជា៖ លក្ខណវិធានប្រភពដើមទំនិញ (rules of origin) មានលក្ខណៈសាមញ្ញ និងពន្ធនាំចូលមានកម្រិតទាប។

លោកស្រីបានមានប្រសាសន៍ទៀតថា លោកស្រីសូមលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងប្រទេសកម្ពុជាឱ្យចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាសាធារណៈរបស់រាជរដ្ឋាភិបាលអង់គ្លេស លើវិធានការពាណិជ្ជកម្មថ្មី ដែលកិច្ចពិគ្រោះយោបល់ដ៏សំខាន់នេះនឹងជួយប្រទេសនានាប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ កិច្ចពិគ្រោះយោបល់នេះធ្វើឡើងរយៈពេល ០៨សប្តាហ៍ ដើម្បីប្រមូលនូវធាតុចូលនានាពីពាណិជ្ជករ សមាគមអ្នកប្រើប្រាស់ ដៃគូរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដែលមានចំណាប់អារម្មណ៍ រួមទាំងសាធារណជនផងដែរ។

សូមបញ្ជាក់ដែរថា គិតចាប់ពីត្រីមាសទី១ ដល់ចុងត្រីមាសទី៤ ឆ្នាំ២០២០ ពាណិជ្ជកម្មទ្វេភាគីរវាងចក្រភពអង់គ្លេស និងកម្ពុជា មានចំនួន ១,០១៤ប៊ីលានដុល្លារអាមេរិក ហើយអាចនឹងកើនឡើងបន្ថែមទៀត៕

*ដោយ ស៊ិន សុភាក៉*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Khmer Times ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១*

### ការនាំចេញកម្ពុជាសម្រេចបាន ៨ប៊ីលានដុល្លារអាមេរិក គិតត្រឹមឆមាសទី១ ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ KT/Mai Vireak*

ការនាំចេញកម្ពុជា សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ៨,២ប៊ីលានដុល្លារអាមេរិក នៅក្នុងឆមាសទី១ ឆ្នាំ២០២១ ពោលគឺកើនឡើង១៧% ធៀបនឹងឆមាសទី១ ឆ្នាំ២០២០ នេះបើយោងតាមរបាយការណ៍ចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា។

កំណើននៃការនាំចេញនេះ ត្រូវបានជំរុញដោយកំណើននៃការនាំចេញនូវផលិតផលកាត់ដេរ ផលិតផលមិនមែនកាត់ដេរ និងផលិតផលកសិកម្ម។ ក្នុងនោះ ផលិតផលកាត់ដេររួមមាន៖ សម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ សម្រេចបាន៤,៧ប៊ីលានដុល្លារអាមេរិក កើនឡើង០,៩%លើសពីឆ្នាំមុន។ ចំណែកឯផលិតផលមិនមែនកាត់ដេរមានដូចជា៖ កង់ គ្រឿងបំណែកអេឡិចត្រូនិក គ្រឿងបន្លាស់រថយន្ត និងសម្ភារៈឧស្សាហកម្មផ្សេងៗទៀត ដែលសម្រេចបាន ១,៩ប៊ីលានដុល្លារអាមេរិក ពោលគឺកើនឡើង ៥០% ធៀបនឹងឆមាសទី១ឆ្នាំ២០២០ ខណៈដែលការនាំចេញផលិតផលកសិកម្ម សម្រេចបាន ១,៦ប៊ីលានដុល្លារអាមេរិក។

យោងតាមប្រសាសន៍របស់ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាពេលថ្មីៗនេះ ការនាំចេញផលិតផលមិនមែនកាត់ដេររបស់កម្ពុជានឹងកើនឡើង ខណៈពេលដែលការនាំចេញផលិតផលកាត់ដេរ ត្រូវបានរំពឹងថានឹងមានការធ្លាក់ចុះ។

បន្ថែមពីនេះ ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និងប្រទេសដែលជាទីផ្សារនាំចេញចម្បងផ្សេងៗទៀត សម្រាប់ផលិតផលមិនមែនកាត់ដេររបស់កម្ពុជា នឹងធ្វើឱ្យសង្វាក់ផលិតកម្មនៅក្នុងប្រទេសមានភាពមមាញឹក។

ការកើនឡើងនៃការនាំចេញ ត្រូវបានមើលឃើញថាជាសញ្ញាវិជ្ជមាន នៅក្នុងផលិតកម្មក្នុងស្រុករបស់កម្ពុជា បើទោះបីជាវិស័យកាត់ដេរបានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការរាតត្បាតនៃជំងឺកូវីដ-១៩ ធៀបនឹងវិស័យផ្សេងៗទៀតក៏ដោយ៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Khmer Times ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១*

## កម្ពុជា គាំទ្រសេចក្តីថ្លែងការណ៍ ស្តីពីនិរន្តរភាព នៃផលិតកម្មកសិកម្ម និងប្រព័ន្ធស្បៀងអាហារ




*ប្រភព៖ dap-news, 2021*

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ក្រោមប្រធានបទស្តីពី និរន្តរភាពនៃផលិតកម្មកសិកម្ម និងប្រព័ន្ធស្បៀងអាហារ (Sustainable Agriculture Productions and Food System)។

កិច្ចប្រជុំនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីពិភាក្សា និងរៀបចំសេចក្តីថ្លែងការណ៍រួម ដោយលោក Nogami Kotaro រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃប្រទេសជប៉ុន គ្រោងនឹងថ្លែងសេចក្តីថ្លែងការណ៍រួមនេះ នៅក្នុងកិច្ចប្រជុំត្រៀមមហាសន្និបាតកំពូលពិភពលោក (Pre-Summit on Food System) នាខែកញ្ញា ២០២១ ខាងមុខ នៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី ក្នុងគោលបំណងទាក់ទាញចំណាប់

អារម្មណ៍ឱ្យប្រទេសទាំងអស់ក្នុងសកលលោក ងាកមកយកចិត្តទុកដាក់លើប្រទេសកសិកម្ម ជាពិសេស ប្រទេសក្នុងតំបន់ខ្យល់មូសុង ព្រោះថាការប្រែប្រួលអាកាសធាតុគឺជាកត្តាដ៏សំខាន់ដែលជះឥទ្ធិពលដល់និរន្តរភាព នៃផលិតកម្មកសិកម្ម និងប្រព័ន្ធស្បៀងអាហាររបស់ប្រទេសសមាជិកអាស៊ាន ។ ហេតុដូច្នេះ សេចក្តីថ្លែងការណ៍រួមនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមយ៉ាងសកម្ម ជាមួយប្រទេសជាសមាជិក ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ក្នុងការជួយដល់ប្រទេស ដែលពឹងផ្អែកលើផលិតកម្ម កសិកម្មជាចម្បង ទាំងធនធានហិរញ្ញវត្ថុ និងបច្ចេកទេសកសិកម្មទំនើប។

កម្ពុជាគាំទ្រ សេចក្តីថ្លែងការណ៍រួមស្តីពី «និរន្តរភាពនៃផលិតកម្មកសិកម្ម និងប្រព័ន្ធស្បៀងអាហារ» (Sustainable Agriculture Productions and Food System) ព្រោះថា សេចក្តីថ្លែងការនេះស្របតាមគោលនយោបាយ និងផែនការអភិវឌ្ឍ វិស័យកសិកម្មកម្ពុជា ឆ្នាំ២០៣០ ដែលបានដាក់ចេញនូវគោលនយោបាយ រួមមាន៖ ១-ជំរុញផលិតកម្មកសិកម្ម ២-បង្កើនប្រសិទ្ធភាព និងមានភាពប្រកួតប្រជែង និង ៣-ការបង្កើនផលិតកម្មកសិកម្ម ដោយគិតគូរដល់និរន្តរភាពបរិស្ថាន។

*ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ គេហទំព័រដើមអម្ពិល ចេញផ្សាយនៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២១*

## ការផ្គត់ផ្គង់ ជ្រូកសាច់រស់ ក្នុងស្រុកបានហួតដល់ ៨៥%




*រូបភាព៖សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា*

ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២១នេះ ការសុំបង្កើតកសិដ្ឋានចិញ្ចឹមជ្រូក មានចំនួន៦១កន្លែង ក្នុងនោះ កសិដ្ឋានចិញ្ចឹមពូជជ្រូកមានចំនួន៧កន្លែង និងកសិដ្ឋានចិញ្ចឹមជ្រូកសាច់ចំនួន៥៤កន្លែង ហើយក៏មានការនាំចូលពូជជ្រូកមេ បា និងកូនជ្រូកពូជមួយចំនួនទៀត។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ជ្រូកសាច់រស់នៅកម្ពុជាបានហួតដល់៨៥%។

យោងតាមអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកឡើងថា ថ្លៃដើមផលិតជ្រូកសាច់បានប្រែប្រួលក្នុងរង្វង់ពី ៧ ៥០០រៀល ទៅ ៩ ០០០រៀល ក្នុងមួយគីឡូក្រាម មុនវិបត្តិកូវីដ-១៩។ ចំពោះថ្លៃដើមផ្ទុកសាច់ជ្រូក ក៏បានកើនឡើងប្រមាណពី ១០ ៥០០រៀល ទៅ ១២ ០០០រៀល ក្នុងមួយគីឡូក្រាម ដោយសារតម្លៃវត្ថុធាតុដើមដូចជា ពោតដំឡូងក្រៀម សណ្តែកសៀង ម្សៅត្រី និងសារធាតុបន្ថែមសម្រាប់ផ្សំចំណីសត្វ ក៏បានកើនឡើងប្រមាណពី២០% ទៅ ៣០%ដែរ។ បច្ចុប្បន្ននេះ កម្ពុជាពុំដែលបានផ្តល់សិទ្ធិផ្តាច់មុខដល់ក្រុមហ៊ុននាំចូលជ្រូករស់ពី

ប្រទេសថៃឡើយ។ សព្វថ្ងៃ មានក្រុមហ៊ុនចំនួន ០៦ កំពុងទទួលបានគោលការណ៍នាំជ្រូករស់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងមានចំនួន៤ ក្រុមហ៊ុនទទួលគោលការណ៍នាំឆ្លងកាត់។

ទាក់ទងនឹងតម្លៃដឹកជញ្ជូនតាមផ្លូវទឹកវិញ អគ្គនាយកដ្ឋានបានអះអាងថា មានការកើនឡើងប្រមាណ ០៣ដង និង តម្លៃកូនជ្រូកពូជសាច់ក៏កើនបានឡើងពី ៧០$ ទៅ១០០$ក្នុងមួយក្បាល ព្រមទាំងមានការចំណាយបន្ថែមលើការលើកកម្ពស់ជីវសុវត្ថិភាពនៅកន្លែងចិញ្ចឹមសត្វ ដើម្បីការពារជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្ត។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានពិនិត្យឃើញថា ការផ្គត់ផ្គង់ជ្រូកសាច់រស់នៅក្នុងស្រុកបានលទ្ធផលដ៏ល្អនេះ គឺបណ្តាលមកពីការខិតខំប្រឹងប្រែងរបស់មន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលតែងតែពិភាក្សារិះរកដំណោះស្រាយសមស្រប ដើម្បីលើកទឹកចិត្តដល់ការចិញ្ចឹមជ្រូកក្នុងស្រុកបម្រើឱ្យតម្រូវការទីផ្សារ និងឈានឆ្ពោះទៅការនាំចេញនៅពេលខាងមុខដ៏ខ្លី៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ The Cambodia China Times ចេញផ្សាយថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២១*

## ពោតក្រហមនៅខេត្តត្បូងឃ្មុំ កំពុងមានទីផ្សារ និងតម្លៃល្អ ធ្វើឱ្យកសិករកំពុងទទួលបានប្រាក់ចំណេញ



*ប្រភព៖ CNC, 2021*

ពោត គឺជាដំណាំដែលប្រជាពលរដ្ឋ ស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ជាពិសេសអ្នករស់នៅតាមដងទន្លេមេគង្គនិយមដាំ។

អ្នកភូមិបឹងកំបោរ ឃុំបឹងព្រួល ស្រុកត្បូងឃ្មុំ ប្រកបរបរដាំពោតក្រហមជាច្រើនឆ្នាំមកហើយ។ ការដាំពោតក្រហមត្រូវចំណាយពេល ៣ខែ និង១៥ថ្ងៃ ទើបអាចប្រមូលផលបាន បើមានការថែទាំបានល្អ ដូចជាដាក់ជី ស្រោចទឹក។ ទិន្នផលដែលអាចទទួលបានមានប្រមាណ១០តោនក្នុង១ហិកតា និងអាចដាំបាន ២ដងក្នុង១ឆ្នាំ។ បច្ចុប្បន្ននេះ ពោតស្ងួតមានតម្លៃ ១ ២០០រៀលក្នុង១គីឡូក្រាម គឺអាចទទួលបានប្រាក់ចំណេញ។

ស្រដៀងគ្នានេះដែរ កសិករក្នុងឃុំជីរោទី១ ស្រុកត្បូងឃ្មុំ ក៏បានរៀបរាប់ឱ្យដឹងដែរថា ពោតឆ្នាំនេះ មានតម្លៃល្អជាងឆ្នាំមុន ដែលធ្វើឱ្យពួកគាត់អាចទទួលបានប្រាក់ចំណេញ។ សម្រាប់ការដាំពោតក្រហមនេះ ពួកគាត់អាចដាំបាន ២ដងទៅ៣ដងដែរក្នុង១ឆ្នាំ ប៉ុន្តែការដាំលើកទី៣ ជាការផ្សងសំណាងណាស់ ព្រោះប្រឈមនឹងការលិចលង់ខូច ដោយទឹកទន្លេមេគង្គ ប៉ុន្តែបើសិនមិនមានការលិចទឹកទេ ទិន្នផលអាចផ្តល់ប្រាក់ចំណេញច្រើន។

លោក ហេង ពិសិដ្ឋ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ បានឱ្យដឹងថា ក្នុងខេត្តត្បូងឃ្មុំទាំងមូល ការដាំដុះពោតទាំងរដូវប្រាំង និងរដូវវស្សា មានប្រមាណជាង ១ម៉ឺនហិកតា ក្នុងនោះកសិករបានជ្រើសពូជជាច្រើនប្រភេទ តាមការនិយមដែលធ្លាប់បានដាំ និងបានទទួលទិន្នផលខ្ពស់៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី ២០-កក្កដា-២០២១*

## តារាងប្រចាំសប្តាហ៍ ៖

### តារាងទី១៖ ពាណិជ្ជកម្មរបស់កម្ពុជាប្រចាំត្រីមាសទី១ ឆ្នាំ២០២១ (គិតជាលានដុល្លារអាមេរិក)

| បរិយាយ | ត្រីមាសទី១ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៩ | ២០២០ | ២០២១ | ២០២១ |
| ពាណិជ្ជកម្មអន្តរជាតិ | | | | |
| ទំហំនាំចេញ | 3,219.50 | 3,557.90 | 3,805.80 | 7.0% |
| ទំហំនាំចូល | 4,442.70 | 5,051.80 | 7,514.20 | 48.7% |
| តុល្យភាពពាណិជ្ជកម្ម | (1,223.20) | (1,493.90) | (3,708.40) | 148.2% |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

*ប្រភព៖ ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១*

តារាងទី១នេះ បង្ហាញពីការនាំចេញរបស់កម្ពុជា ក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជិត ៧%។ ការកើនឡើងនេះ គឺដោយសារកំណើននៃផលិតផលមិនមែនកាត់ដេរ បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០២០ នេះបើយោងតាមព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជាក់ស្តែងគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២១ ការនាំចេញទំនិញមានទំហំគិតជាទឹកប្រាក់សរុបប្រមាណ ៣ ៨០៦ លានដុល្លារ ឬ កើន ២៤៨លានដុល្លារ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ការកើនឡើងនេះដោយសារកំណើននៃផលិតផលមិនមែនកាត់ដេរ ដែលរួមមាន៖ កង់ គ្រឿងអេឡិចត្រូនិក ផលិតផលកសិកម្ម និងខ្សែភ្លើង ជាដើម។ ទន្ទឹមនឹងនេះ ការនាំចូលទំនិញមានទំហំទឹកប្រាក់សរុបប្រហែល ៧ ៥១៥ លានដុល្លារ ឬកើនប្រមាណ ៤៩% ដោយសារកំណើននៃការនាំចូលវាយនភណ្ឌនិងសម្លៀកបំពាក់ បរិក្ខារសំណង់ ថ្នាំពេទ្យ និងគ្រឿងឧបភោគបរិភោគ បើធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២០។

ដោយឡែក ឱនភាពពាណិជ្ជកម្មមានតម្លៃសរុបប្រមាណ ៣ ៧០៨ លានដុល្លារ ឬកើនឡើង១៤៨% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១៕

***ដោយ ឈន ហ៊ាំ***

### តារាងទី២៖ កំណើនថយចុះ ៨,៩% នៃការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០២១




*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០២១*

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(អគរ) បានបង្ហាញថា ការអនុវត្តលើការប្រមូលចំណូល បានថយចុះប្រមាណ ៨,៩% ក្នុងឆមាសទី១ ឆ្នាំ២០២១។

ជាក់ស្តែង ក្នុងឆមាសទី១ ឆ្នាំ២០២១នេះ អគរ ប្រមូលចំណូលបានចំនួន ៤ ៦៩៥,៨ ប៊ីលានរៀល ស្មើនឹង ១ ១៥៩,៥ លានដុល្លារ ឬ ថយចុះ ៤៥៦,៨ ប៊ីលានរៀល បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ក្នុងនោះដែរ បើគិតតាមប្រភេទពន្ធ និងអាករមួយចំនួន នៃចំណូលសរុបខាងលើនេះ អាករលើតម្លៃបន្ថែមមានប្រមាណ ៣៧,៨%, អាករពិសេស៣៧,៦%, ពន្ធគយ ១៨,១%, អាករបន្ថែមលើផលិតផលប្រេង ៤,៥%, និងអាករនាំចេញនិងកម្រៃផ្សេងៗ ២% ។

ដោយឡែក បើគិតតាមក្រុមទំនិញវិញធៀបនឹងចំណូលសរុបខាងលើ ចំណូលពីយានយន្ត និងគ្រឿងចក្រមានប្រមាណ៤២,៣%,ទំនិញចម្រុះ២៨%, ផលិតផលសេលសិលា២៣,៥% និងសម្ភារសំណង់និងកម្រៃផ្សេងៗ៦,២% ។

ជាលទ្ធផលការប្រមូលចំណូលក្នុងឆមាសទី១នេះ គឺសម្រេចបាន ៤៩% នៃផែនការ ដែលកំណត់ដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១៕
*ដោយ ឈន ហ៊ាំ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ក្រសួងហិរញ្ញវត្ថុរបស់ប្រទេសវៀតណាម បានស្នើដំឡើងអត្រាពន្ធគយលើការនាំចេញនូវផលិតផលមាស



*ប្រភព៖vietnamnews, 2021 រូបភាព៖ Ly Ly Cao*

ក្រសួងហិរញ្ញវត្ថុនៃប្រទេសវៀតណាមកំពុងរៀបចំសេចក្តីព្រាងស្តីពីពន្ធលើការនាំចេញ ការអនុគ្រោះពន្ធនាំចូល បញ្ជីទំនិញ និងពន្ធគយក្នុងអត្រាថេរ ពន្ធចម្រុះ និងពន្ធនាំចូលមិនមានកំណត់កូតា ដោយក្នុងនោះរួមមានការស្នើដំឡើងពន្ធនាំចេញសម្រាប់ផលិតផលមាស ដែលមានបន្សុទ្ធភាពតិចជាង៩៥% ក្នុងអត្រា២% ដែលកន្លងមកគិតក្នុងអត្រា០%។

សូមបញ្ជាក់ផងដែរ ក្រុមហ៊ុនទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យនាំចេញប្រភេទមាសមិនទាន់កែច្នៃនោះទេ គឺអនុញ្ញាតចំពោះតែប្រភេទមាសដែលបានកែច្នៃជាប្រភេទគ្រឿងអលង្ការ ហើយមានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវ។ ប៉ុន្តែ បច្ចុប្បន្ននេះសហគ្រាសបានធ្វើការនាំចេញមាសដោយប្រកាសថាជាមាសដែលបានកែច្នៃ ហើយមានបន្សុទ្ធភាពតិចជាង ៩៥% ជាមួយអត្រាពន្ធគយ នាំចេញ ០ %។

ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឱ្យដឹងថាទីផ្សារមាសក្នុងពិភពលោក និងក្នុងស្រុក មានការប្រែប្រួលយ៉ាងខ្លាំងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក សង្គ្រាមពាណិជ្ជកម្ម ក៏ដូចជាការធ្លាក់ចុះយ៉ាងខ្លាំងនៃប្រាក់ដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងរូបិយប័ណ្ណសំខាន់ៗដទៃទៀត និងជាពិសេសភាពស្មុគស្មាញនៃជំងឺរាតត្បាតសកល ដែលប៉ះពាល់ដល់វិនិយោគិននៅទូទាំងពិភពលោក។

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានគយបានបង្ហាញថា ក្នុងឆមាសទី ១ ឆ្នាំនេះ ការនាំចេញមាសមានទំហំ ៣៨០ លានដុល្លារអាមេរិក។ កាលពី ឆ្នាំ ២០២០ ការនាំចេញមានទឹកប្រាក់ចំនួន ២,៦ប៊ីលានដុល្លារកើនឡើងជាង ៦០០ លានដុល្លារបើប្រៀបធៀបនឹងឆ្នាំ ២០១៩ និងកើនជាង ២ ប៊ីលានដុល្លារធៀបនឹងពេលដូចគ្នានៃឆ្នាំ ២០១៨ ។ ក្នុងនោះមានសហគ្រាសចំនួន ៤៦៩ ដែលនាំចេញនិងនាំចូល

ផលិតផលមាសរួមមាន៖ គុជត្បូង ពេជ្រត្បូងមានតម្លៃ និងផលិតផលគ្រឿងអលង្ការធ្វើពីវត្ថុធាតុដើមផ្សេងទៀត និងកាក់ដែក។ *ដោយ សេន ចន្ទី*

*ប្រភព៖Vietnamnews.ចេញផ្សាយថ្ងៃទី១៩ខែកក្កដាឆ្នាំ២០២១*

## ពិដានថវិកាឆ្នាំ២០២២ របស់ប្រទេសហ្វីលីពីនត្រូវបានកម្រិតក្នុងបរិមាណជាង ៥ទ្រីលានប៉េសូ



*ប្រភព៖ABS-CBN, 2021*

យោងតាមការបង្ហាញរបស់គណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍថវិកា (DBCC) ៖ រដ្ឋាភិបាលរបស់ប្រទេសហ្វីលីពីន គ្រោងចំណាយថវិកាចំនួន ៥,៥២ទ្រីលានប៉េសូ សម្រាប់ឆ្នាំ២០២២ ដែលកើនឡើង១១,៥%ធៀបនឹងថវិកានៅឆ្នាំនេះ។

សម្រាប់ចំណាយថវិកាឆ្នាំ២០២២ដែលបានគ្រោងនេះ ថវិកាប្រមាណ ១,២៩ទ្រីលានប៉េសូ សមាមាត្រនឹង ៥,៨%នៃផ.ស.ស ត្រូវបានចំណាយសម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលនៅឆ្នាំក្រោយ។ ទន្ទឹមនឹងនេះថវិកាជាតិឆ្នាំ២០២២ នៅតែបន្តវិនិយោគក្នុងការកសាងភាពធន់របស់ប្រទេស ចំពេលដែលប្រទេសកំពុងជួបប្រទះនូវវិបត្តិជំងឺកូវីដ-១៩ ដោយផ្តល់អាទិភាពដល់មូលនិធិសម្រាប់វិធានការឆ្លើយតបនឹងជំងឺកូវីដ-១៩ ដូចជាការអភិវឌ្ឍសុខភាព និងសេវាកម្មសង្គម ស្របនឹងការបង្កើនកំណើនសេដ្ឋកិច្ចតាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

DBCC បានបន្តការលើកឡើងថា ប្រទេសហ្វីលីពីនកំពុង ប្រកាន់ខ្ជាប់គោលដៅកំណើនសេដ្ឋកិច្ចពី ៦% ទៅ ៧%សម្រាប់ឆ្នាំ ២០២១ ទោះបីជាមានការកើនឡើងករណីជំងឺកូវីដ-១៩ និងការបិទខ្ទប់ដែលបានកំណត់នៅក្នុងខែមីនា និងខែមេសា។

ចំណែកការធ្វើពាណិជ្ជកម្មវិញគឺ ការនាំចេញទំនិញនៅឆ្នាំនេះត្រូវបានមើលឃើញថាកំពុងកើនឡើង ១០% ពោលគឺកើនឡើងពីការព្យាករមុន ៨ %បន្ទាប់ពីមានការស្ទុះងើបឡើងវិញនៃតម្រូវការខាងក្រៅ។ សម្រាប់កំណើននៃការនាំចេញសេវាកម្មក្នុងឆ្នាំ ២០២២ ត្រូវបានព្យាករថានឹងកើនឡើងដល់ ៧ % ខុសពីការព្យាករមុន ដែលមានត្រឹម ៦ % ដែលស្របនឹងការព្យាករថានឹងមានភាពប្រសើរឡើងទៅលើការធ្វើដំណើរ និងការបញ្ជាទិញនានា ដោយសារតែការបើកដំណើរការសេដ្ឋកិច្ច ឡើងវិញជាបណ្តើរ ៗ។ សូមបញ្ជាក់ផងដែរ កាលពីខែឧសភា DBCC បានទម្លាក់ការព្យាករកំណើនសេដ្ឋកិច្ចរបស់ខ្លួនដំបូងចន្លោះពី ៦,៥ ទៅ៧,៥% មកត្រឹមចន្លោះពី ៦ទៅ៧% បន្ទាប់ពីមានការរីករាលដាលសារជាថ្មីនៃជំងឺកូវីដ-១៩ និងការដាក់ចេញវិធានការឡើងវិញដែលជាហេតុនាំឱ្យមានការរារាំងដល់កំណើនសេដ្ឋកិច្ច។ *ដោយ សេន ចន្ទី*

*ប្រភព៖ news.abs-cbn.com ចេញផ្សាយថ្ងៃទី១៩ខែកក្កដាឆ្នាំ២០២១*

## អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូណេស៊ី សម្រាប់ខែមិថុនា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិឥណ្ឌូណេស៊ី (BPS) បានបង្ហាញថា ឥណ្ឌូណេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន ១,៣២ ពាន់លានដុល្លារអាមេរិក នៅក្នុងខែមិថុនាឆ្នាំ២០២១ ហើយចាប់ពីខែឧសភាឆ្នាំ២០២០ ដល់ខែមិថុនាឆ្នាំ

២០២១ តុល្យភាព ពាណិជ្ជកម្មរបស់ប្រទេសនេះ តែងតែមានអតិរេក។

អតិរេកភាគច្រើនបានមកពីវិស័យមិនមែនប្រេង និងឧស្ម័នចំនួន ២,៣៨ពាន់លានដុល្លារ ខណៈដែលវិស័យប្រេង និងឧស្ម័នមានឱនភាពចំនួន ១,០៦ ពាន់លានដុល្លារ។

តម្លៃនាំចេញសរុបនៅក្នុងខែមិថុនា ឆ្នាំ២០២១ មានចំនួន ១៨,៥៥ ពាន់លានដុល្លារអាមេរិក ហើយការនាំចូលមានតម្លៃ ១៧,២៣ ពាន់លានដុល្លារអាមេរិក កើន ៥៤,៤% និង ៦០,១២% រៀងគ្នា ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុខ ដែលជាកំណើនខ្ពស់បំផុតក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ៕ *ដោយ ធឹម ប៊ុនធឿន*

| | មិថុនា ឆ្នាំ ២០២០ | មិថុនា ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|
| **ការនាំចេញ** | 12.01 | 18.55 | 54.5 |
| **ការនាំចូល** | 10.76 | 17.23 | 60.1 |
| **តុល្យភាព ពាណិជ្ជកម្ម** | 1.25 | 1.32 | 5.6 |

*ប្រភព៖ Central Bureau of Statistics ( bps.go.id )*

## ពាណិជ្ជកម្មថៃ ជាមួយដៃគូសំខាន់ៗ សម្រាប់ ត្រីមាសទី១ ឆ្នាំ២០២១

ក្រាហ្វិចខាងក្រោមបង្ហាញពីពាណិជ្ជកម្ម រវាងប្រទេសថៃ និងដៃគូសំខាន់ៗរបស់ខ្លួន សម្រាប់ត្រីមាសទី១ ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចេញរបស់ថៃ ទៅកាន់បណ្តាប្រទេសអាស៊ាន បានថយចុះ ៥,៥% ពី១៦ ២៥៣ លានដុល្លារអាមេរិក សម្រាប់ត្រីមាសទី១ ឆ្នាំ២០២០ មកនៅ ១៥ ៣៥៩ លានដុល្លារអាមេរិក សម្រាប់ត្រីមាសទី១ឆ្នាំ២០២១ ខណៈការនាំចូលមានការកើនឡើងបន្តិចបន្តួច។

ថៃមានតុល្យភាពពាណិជ្ជកម្មវិជ្ជមានជាមួយសហរដ្ឋអាមេរិក ដែលបានកើនឡើងពី ២ ៨៣៩ លានដុល្លារអាមេរិក នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០ ដល់ ៦ ០១៦ លានដុល្លារអាមេរិក នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១។ ការណ៍នេះ ភាគច្រើនបណ្តាលមកពីការថយចុះនៃការនាំចូលពីសហរដ្ឋអាមេរិក។

ចំណែកឯការធ្វើពាណិជ្ជកម្មរបស់ប្រទេសថៃ ជាមួយចិន និងជប៉ុនវិញ មានឱនភាព ដោយសារមានការនាំចូលពីប្រទេសទាំងពីរនោះកាន់តែច្រើន ខណៈដែលការនាំចេញរបស់ថៃមានការកើនឡើងតិចតួច។

ស្រដៀងគ្នាផងដែរ តុល្យភាពពាណិជ្ជកម្មជាមួយអឺរ៉ុបមានឱនភាពបន្តិច ដែលនេះជាលើកដំបូងក្នុងរយៈពេលដ៏យូរ ដោយសារការនាំចូលមាសកើនឡើង។ ជារួម ពាណិជ្ជកម្មរបស់ថៃ គឺប្រហាក់ប្រហែលទៅនឹងឆ្នាំមុនៗដែរ។ ប្រទេសថៃ មានអតិរេកពាណិជ្ជកម្មជាមួយបណ្តាប្រទេសអាស៊ាន និងអាមេរិក ប៉ុន្តែ មានឱនភាពពាណិជ្ជកម្មជាមួយចិន និងជប៉ុន ស្របពេលពាណិជ្ជកម្មជាមួយអឺរ៉ុបកាន់តែមានតុល្យភាព៕ *ដោយធឹម ប៊ុនធឿន*




*ប្រភព៖ https://www.thaiwebsites.com*

# សេដ្ឋកិច្ចសកល

## ការលក់រាយរបស់សហរដ្ឋអាមេរិក កើនឡើង0.6% ក្នុងខែមិថុនា

ការលក់រាយរបស់សហរដ្ឋអាមេរិក បានកើនឡើងដោយមិននឹកស្មានដល់នៅក្នុងខែមិថុនា ដោយសារតម្រូវការទំនិញនៅតែមានភាពរឹងមាំ នៅពេលការចំណាយកំពុងផ្លាស់ប្តូរទៅកាន់ផ្នែកសេវាកម្មវិញក៏ដោយ។ ការណ៍នេះជំរុញអោយមានការរំពឹងទុកថាកំណើនសេដ្ឋកិច្ច នឹងមានការកើនឡើងនៅក្នុងត្រីមាសទី ២។

ក្រសួងពាណិជ្ជកម្ម បានរាយការណ៍អំពីការកើនឡើងនៃការលក់ ទោះបីជាការទិញយានយន្តធ្លាក់ចុះជាថ្មីក៏ដោយ (ដោយសារកង្វះការផ្គត់ផ្គង់ ដែលបណ្តាលមកពីកង្វះខាតវត្ថុធាតុដើមអេឡិចត្រូនិក (semiconductor) សាកល)។ ភាពខ្វះខាតនៃយានយន្តថ្មីៗ កំពុងជំរុញតម្រូវការរថយន្ត និងរថយន្តដឹកទំនិញប្រើប្រាស់រួចដែលជួយជំរុញអតិផរណា។ ម្យ៉ាងទៀត ការចាក់វ៉ាក់សាំងកូវីត-១៩ អត្រាការប្រាក់ទាប និងការជំរុញសារពើពន្ធដ៏ច្រើនកំពុងជួយដល់ការលក់រាយ។

ទន្ទឹមនឹងនេះ ការលក់រាយ បានកើនឡើង ០,៦% កាលពីខែមុន។ ទិន្នន័យនាខែឧសភា ត្រូវបានកែលម្អឡើងវិញ ដែលបានបង្ហាញថាការលក់ធ្លាក់ចុះ១,៧% ជំនួសឱ្យការធ្លាក់ចុះ១,៣%ដែលបានរាយការណ៍ពីមុន។ ជាមួយគ្នានេះ បើប្រៀបធៀបនឹងខែមិថុនាឆ្នាំមុន ការលក់បានកើនឡើង ១៨,០% ដែលខ្ពស់ជាងកម្រិតមុននៃការរាតត្បាតជំងឺ ហើយតម្រូវការ បានផ្លាស់ប្តូរទៅរកទំនិញ ដូចជាគ្រឿងអេឡិចត្រូនិច និងយានយន្ត ក្នុងពេលមានការរីករាលដាលជំងឺ ដោយសារមនុស្សរាប់លាននាក់ធ្វើការពីផ្ទះ រៀនតាមប្រព័ន្ធអ៊ីនធឺណេត និងជៀសវាងការធ្វើដំណើរតាមមធ្យោបាយសាធារណៈ។ ម្យ៉ាងវិញទៀត សន្ទស្សន៍ភាគហ៊ុនអាមេរិកបានកើនឡើង ប្រាក់ដុល្លារ មានស្ថេរភាពធៀបនឹងរូបិយប័ណ្ណនានា ខណៈដែលទិន្នផលរតនាគារសហរដ្ឋអាមេរិកមានការកើនឡើង។

ដោយឡែក ការព្យាករកំណើនផ.ស.ស សម្រាប់ត្រីមាសនេះ គឺមានអត្រា៩% ដែល កើនឡើងពីអត្រា ៦,៤% នៅក្នុងត្រីមាសទី១។ សេដ្ឋវិទូជឿជាក់ថា សេដ្ឋកិច្ចអាចសម្រេចបានកំណើនយ៉ាងតិច ៧% នៅឆ្នាំនេះ ដែលនោះជាកំណើនលឿនបំផុតចាប់តាំងពីឆ្នាំ ១៩៨៤ ខណៈពេលដែលសេដ្ឋកិច្ចនេះ បានធ្លាក់ចុះ ៣.៥% នៅឆ្នាំ២០២០ ដែលជាដំណើរការអាក្រក់បំផុតក្នុងរយៈពេល ៧៤ ឆ្នាំ។ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១*

## ការធ្លាក់ចុះសេដ្ឋកិច្ចសហរដ្ឋអាមេរិក បានបញ្ចប់នៅខែមេសា ឆ្នាំ ២០២០ ដែលជាកំណត់ត្រាខ្លីបំផុត




*ប្រភព៖ Reuters ២០២១, រូបភាព៖ Reuters/Jeenah Moon*

វិបត្តិសេដ្ឋកិច្ចរបស់អាមេរិក ដែលរងឥទ្ធិពលពីផលប៉ះពាល់ដោយការឆ្លងរីករាលដាលដោយជំងឺកូវីដ១៩ មានរយៈពេលតែពីរខែប៉ុណ្ណោះ ដោយបញ្ចប់ជាមួយនឹងកម្រិតទាបមួយ ក្នុងខែមេសាឆ្នាំ ២០២០ បន្ទាប់ពីការធ្លាក់ចុះយ៉ាងខ្លាំងនៃសកម្មភាពសេដ្ឋកិច្ចនៅខែមីនានៃឆ្នាំនោះ នេះបើ យោងតាមគណៈកម្មាធិការដែលជាក្រុមសេដ្ឋវិទូម៉ាក្រូសេដ្ឋកិច្ច ជាអ្នកកំណត់កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់នៃវដ្តអាជីវកម្មរបស់សហរដ្ឋអាមេរិក។

ជាមួយគ្នានេះ គណៈកម្មាធិការនេះ បានលើកឡើងថា ខណៈដែលសេដ្ឋកិច្ចសហរដ្ឋអាមេរិក មិនបានវិលត្រឡប់ទៅរកសមត្ថភាពប្រតិបត្តិការធម្មតាវិញនៅពេលនោះ សូចនាករទាំងការងារ និងផលិតកម្ម ក្នុងខែមេសាឆ្នាំ២០២០ មានការដាំក្បាលចុះ" ប៉ុន្តែមានការស្ទុះងើបឡើងវិញនៅដើមខែឧសភា។

ការចាប់ផ្តើមកំណើនឡើងវិញនេះ យ៉ាងឆាប់រហ័សដូច្នេះ គឺ វាគ្រាន់តែជា "ការថយចុះ ដែលមិនបានរំពឹងទុក" ដែលនាំឱ្យសមាជិកនៃគណៈកម្មាធិការពិចារណាពីអ្វីដែលបានកើតឡើងចំពោះវិបត្តិសេដ្ឋកិច្ចដំបូង ដោយផ្តោតទៅលើ "ជម្រៅ រយៈពេល និងការសាយភាយ" ដើម្បីកំណត់បាននូវមូលហេតុជាក់លាក់នៃការធ្លាក់ចុះ។ ការងារប្រហែល ២២ លានកន្លែង បានបាត់ពីបញ្ជីបើកប្រាក់ខែរបស់ក្រុមហ៊ុននៅក្នុងខែមីនា និងមេសា ក្នុងឆ្នាំនោះ ដែលជាព្រឹត្តិការណ៍មួយដែលបង្កឱ្យមានការព្រួយបារម្ភអំពីវិបត្តិសេដ្ឋកិច្ចថ្មី និងនាំអោយសមាជិកសភា និងសេតវិមាន អនុម័តលើកញ្ចប់ថវិកាសង្គ្រោះដំបូងជាច្រើនដើម្បីរក្សាក្រុមហ៊ុន និងគ្រួសារ។

ការកំណត់កាលបរិច្ឆេទបញ្ចប់វិបត្តិសេដ្ឋកិច្ច គឺជាកំណត់ត្រាប្រវត្តិសាស្ត្រមួយ ហើយក្នុងករណីនេះ យើងក៏ត្រូវ ការស្រាវជ្រាវការវិវឌ្ឍន៍នៃវដ្តអាជីវកម្មផងដែរ ថាតើមានគោលនយោបាយ ការឆ្លើយតប ជាប្រវត្តិសាស្ត្របែបណា ក្នុងការដោះស្រាយវិបត្តិខាងលើនេះ។ ការប្រកាសនេះ បានធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច ដែលបណ្តាលមកពីការរាតត្បាតជំងឺមានកំណត់ត្រាជារយៈពេលខ្លីបំផុត ដែលមាន រយៈពេលត្រឹមពី ២ខែ ស្មើនឹងមួយភាគបីនៃការធ្លាក់ចុះ៦ខែ កាលពីដើមឆ្នាំ១៩៨០ និងស្មើមួយភាគបួន នៃរយៈពេលវិបត្តិសេដ្ឋកិច្ច ក្រោយពីការដួលរលំនៃពពុះបច្ចេកវិទ្យា កាលពីឆ្នាំ២០០១។ ជាមួយគ្នានេះ វាអាចផ្តល់ជាអំណះអំណាងក្នុងការគាំទ្រដល់អ្នកធ្វើគោលនយោបាយសារពើពន្ធ វិធានប្រាក់ដំបូង"cash-first" ក្នុងការប្រយុទ្ធប្រឆាំងនឹងរោគរាតត្បាតនេះ តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភគ្រួសារម្តងហើយម្តងទៀត,ការពង្រីកអត្ថប្រយោជន៍ដល់អ្នកគ្មានការងារធ្វើ និងការផ្តល់នូវហិរញ្ញប្បទាន សម្រាប់អាជីវកម្មខ្នាតតូច។

*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Rruters ចុះថ្ងៃទី20 ខែកក្កដា ឆ្នាំ២០២១*

## ប្រទេសជប៉ុន រក្សាការវាយតម្លៃសេដ្ឋកិច្ចនៅក្នុងរបាយការណ៍ខែកក្កដា




*ប្រភព ៖ សាន លីម៉ា*

ប្រទេសជប៉ុន បានវាយតម្លៃសេដ្ឋកិច្ចរបស់ខ្លួនក្នុងរយៈពេលពីរខែជាប់គ្នានៅក្នុងខែកក្កដា ថាលក្ខខ័ណ្ឌនៅតែធ្ងន់ធ្ងរ ដោយសារតែផលប៉ះពាល់នៃជំងឺរាតត្បាតកូវីឌ-១៩។

លោកនាយករដ្ឋមន្ត្រី Yoshihide Suga បានលើកឡើងថា ជប៉ុនត្រូវយកចិត្តទុកដាក់ឱ្យបានពេញលេញចំពោះផលប៉ះពាល់នៃជំងឺរាតត្បាត ដែលកំពុងជះឥទ្ធិពលដល់សេដ្ឋកិច្ចក្នុងស្រុក និងនៅបរទេស។ លោកបានបន្តថា រដ្ឋាភិបាលជប៉ុន បានវាយតម្លៃអំពីស្ថានភាពសេដ្ឋកិច្ច ហើយបានបង្ហាញថា សេដ្ឋកិច្ចនូវមានភាពទន់ខ្សោយ ទោះបីជាសេដ្ឋកិច្ចបន្តមានកំណើន ចំពេលមានស្ថានភាពធ្ងន់ធ្ងរដោយសារមេរោគនេះក៏ដោយ។ សមាសធាតុសេដ្ឋកិច្ចសំខាន់ៗជំរុញកំណើនមានដូចជា ការប្រើប្រាស់ឯកជន មានចំនួនច្រើនជាងពាក់កណ្តាលនៃផលិតផលក្នុងស្រុកសរុប និងកំណើននៃការនាំចេញ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ចក្រៅប្រទេស ដែលជំរុញឱ្យមានការងើបឡើងវិញនៃស្ថានភាពអាជីវកម្ម។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ SWIFT NEWS ចេញផ្សាយថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៦ ខែកក្កដា ឆ្នាំ២០២១

- អត្រាអ្នកអត់ការងារធ្វើនៅម៉ិកស៊ិក បានធ្លាក់ចុះដល់៤,០% នៅក្នុងខែឧសភាឆ្នាំ ២០២១
- កំណើនបំណុលរដ្ឋាភិបាលរបស់ទួរគី ក្នុងខែឧសភា ឆ្នាំ២០២១ ។

ថ្ងៃអង្គារ ទី២៧ ខែកក្កដា ឆ្នាំ២០២១

- កំណើន ផ.ស.ស របស់កូរ៉េខាងត្បូងបានកើន ១,៧ ភាគរយនៅត្រីមាសក្នុងរយៈពេល ៣ ខែដល់ខែមីនាឆ្នាំ២០២១
- កំណើន ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសប្រេស៊ីល ក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃពុធ ទី២៨ ខែកក្កដា ឆ្នាំ២០២១

- អត្រាអតិផរណាប្រចាំឆ្នាំ នៅក្នុងប្រទេសអូស្ត្រាលី បានកើនឡើងដល់១,១% ក្នុងត្រីមាសទី១ ឆ្នាំ២០២១
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅអូស្ត្រាលី បានកើនឡើង ០,៦០% នៅខែមីនាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី២៩ ខែកក្កដា ឆ្នាំ២០២១

- ការវិនិយោគភាគហ៊ុនដោយជនបរទេស នៅក្នុងប្រទេសជប៉ុនបានថយចុះ គិតត្រឹមថ្ងៃទី ១០ ខែកក្កដាឆ្នាំ ២០២១
- អត្រានីកម្មភាពតាមរដូវកាល នៅប្រទេសអាល្លឺម៉ង់ បានធ្លាក់ចុះមកនៅត្រឹម ៣,៧% ក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី៣០ ខែកក្កដា ឆ្នាំ២០២១

- កំណើនផលិតកម្មឧស្សាហកម្ម នៅកូរ៉េខាងត្បូង បានកើនឡើង ១៦,៦% នៅក្នុងខែឧសភាឆ្នាំ ២០២១ ដែលជាល្បឿនលឿនបំផុត
- កំណើនអត្រានីកម្មភាព នៅប្រទេសជប៉ុន បានកើនឡើងដល់ ៣,០% នៅខែឧសភាឆ្នាំ ២០២១ ពី២,៨%ក្នុងមួយខែមុន៕